ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២៩/២០ - អេច ស៊ី ស៊ី គ្រុប
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០
យោបល់ជំទាស់ទៅនឹងសេចក្តីបង្គាប់ ៖ ដោយអាជ្ញាកណ្តាល យូ សួនទី

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ យូ សួនទី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អាន វីរៈ
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លៈ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប**
អាសយដ្ឋាន ៖ ភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០១៥ ៦១ ២៧ ៤៤ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក Paul Clements | ប្រធានចាត់ការទូទៅស្តីទី |
| ២- លោក ផាត សុតន្ត | ប្រធានផ្នែកលក់ |
| ៣- លោក គឹម សេង | ប្រធានផ្នែកសហប្រតិបត្តិការ |
| ៤- លោក ឌឹម លៀម | ប្រធានផ្នែកធនធានមនុស្ស |
| ៥- លោក ឈុំ សុផេន | អនុប្រធានសាខា |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប**
អាសយដ្ឋាន ៖ ភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០១២ ៩៧ ៨០ ០៧/០៩៥ ៣៧ ៥៤ ៨៩ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ព្រិត សុអួត | មន្ត្រីច្បាប់ACIL |

២- លោក វ៉ែន រ៉ាវ៉ាន់ ប្រធានសហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា

៣- លោក ហ៊ិន ប៊ុនហ៊ុន អនុប្រធានសហជីពមូលដ្ឋាន

៤- លោកស្រី ឡី ស្រីអូន លេខាធិការសហជីពមូលដ្ឋាន

៥- កញ្ញា ឿន ចាន់សេរីវ័ត្ន ហិរញ្ញិកសហជីពមូលដ្ឋាន

៦- លោកស្រី ឡី សំណាង ទីប្រឹក្សាសហជីពមូលដ្ឋាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ចំណុចទាមទារទី១ និងទី២ ៖ មានខ្លឹមសារទាមទារផលប្រយោជន៍ដូចគ្នា គឺភាគីកម្មករទាមទារ ឱ្យក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប (ការិការី) រក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតជាធម្មតា ដោយមិនមានកាត់បន្ថយអត្ថប្រយោជន៍ណាមួយឡើយ។

ភាគីនិយោជក សុំឱ្យភាគីកម្មករនិយោជិតដាក់សំណើសុំប្រាក់ឈ្នួល ៥០% (ហាសិបភាគរយ) មកក្រុមហ៊ុន ដើម្បីតំណាងខាងក្រុមហ៊ុនបញ្ជូនសំណើសុំ ទៅស្នើសុំការសម្រេចរបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។

ភាគីកម្មករនិយោជិត បានអះអាងថា ក្រុមហ៊ុននៅដំណើការនៅឡើយ ដោយប្រើប្រាស់កម្មករនិយោជិតចំនួន ៦នាក់ ដោយបានប្រាក់ឈ្នួលពេញ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី ១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប លេខ ០៣១ ម.ក.ប ចុះថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ០៩ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់សហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជា នៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររួមចំនួន ២ចំណុច។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានអញ្ជើញភាគីទាំងពីរមកចូលរួមដោះស្រាយវិវាទការងាររួម ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចវិវាទដែលមិនសះជាចំនួន ២ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមរវាងក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប និងសហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជា នៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប លេខ ០៣១ ម.ក.ប ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ២ចំណុចនេះ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ៩ និង ៣០នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ២ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទទាំង ២ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ ទៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់លោក ប៉ូល ឃ្លេមិន ជាប្រធានចាត់ការទូទៅនៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ផ្ទេរសិទ្ធិជូន លោក ឌឹម លៀម លោក គឹម សេង និងលោក ឈុំ សុផេន ជាតំណាងដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន អេច ស៊ី ស៊ី មានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយវិវាទការរួម ចុះថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃ ទី១៥ ខែឧសភា ឆ្នាំ២០២០។

២- លិខិតអញ្ជើញលេខ ០៧៥ មកប ចុះថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប អញ្ជើញភាគីនិយោជកដើម្បីផ្តល់ព័ត៌មានអំពីបណ្តឹងរបស់បុគ្គល។

៣- លិខិតលេខ ០០៣/២០. សកអអកកអសសត. របស់សហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីប្តឹងនិយោជកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប និងក្រុមហ៊ុន អាកាសយានដ្ឋានកម្ពុជា (CAMS/VINCI) ដែលបានកាត់បន្ថយប្រាក់ឈ្នួលកម្មករនិយោជិតធ្វើឱ្យប៉ះពាល់ជីវភាពប្រចាំថ្ងៃយ៉ាងខ្លាំង។

៤- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីនិយោជកនៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០។

៥- លិខិតអញ្ជើញលេខ ០៨២ មកប ចុះថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប អញ្ជើញភាគីនិយោជកដើម្បីផ្សះផ្សាវិវាទការងារ។

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០។

៧- ឯកសារផ្នែកប្រតិបត្តិការប្រចាំនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ស្តីពីបញ្ជីឈ្មោះបុគ្គលិកដែលផ្ទេរទៅទីតាំងផ្សេងៗ

៨- ឯកសារស្តីពីព្រឹត្តិការណ៍ប្រធានស័ក្តិ។

៩- បទប្បញ្ញត្តិ និងលក្ខខណ្ឌទូទៅ ចំពោះកម្មករ និយោជិត និងថ្នាក់ដឹកនាំនៃក្រុមហ៊ុន EnviroCam ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១២។

១០- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ខូអិលធីឌី ចុះទិដ្ឋាការ លេខ ០៣១ ក.ក.ប.វ/អក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៥ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

១១- បទបញ្ជាផ្ទៃក្នុងចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៧។

១២- សារណាសង្ខេបនៃវិវាទការងារ។

១៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប លេខ MOC ៤៦០៨៩០៧០ ពណ.ចបព ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០១។

១៤- លក្ខន្តិកៈក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប បានតម្កល់ទុកលេខ ២០២/២០០៣ ពណ.ចបព ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

១៥- សេចក្តីជូនដំណឹងស្តីពីការព្យួរកិច្ចសន្យាការងារបុគ្គលិក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

១៦- លិខិតស្នើសុំលេខ ០១៩/២០២០ ចុះថ្ងៃចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ របស់ក្រុមហ៊ុន EnviroCam គោរពជូន លោកប្រធាន មន្ទីរការងារ

ខេត្តសៀមរាប ស្តីពីសំណើសុំព្យួរកិច្ចសន្យាការងារបុគ្គលិកដែលបម្រើការងារនៅ ទីតាំងព្រលានយន្តហោះអន្តរជាតិសៀមរាបរយៈពេល ២ខែ។

១៧- លិខិតលេខ ០២០/២០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់នាយកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីសំណើសុំព្យួរការងារកម្មករនិយោជិតចំនួន ១១៦នាក់ រយៈពេល ២ខែ។

១៨- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប រយៈពេលព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០។

១៩- លិខិតចុះថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំជូត ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ របស់នាយកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីសំណើសុំព្យួរការងារកម្មករនិយោជិតចំនួន ១៦១នាក់ រយៈពេល ២ខែ។

២០- លិខិតលេខ ០០៩ មកប ចុះថ្ងៃសុក្រ ១កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ជម្រាបមកនាយកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ស្តីពីការបញ្ជាក់ពីការដាក់សំណើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

២១- លិខិតចុះថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំជូត ឯកស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ របស់នាយកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីសំណើសុំឱ្យខាងមន្ទីរការងារជួយបញ្ជាក់ថា ក្រុមហ៊ុន អេច ស៊ី ស៊ី ពិតជាបានបញ្ជូនសំណើសុំព្យួរកិច្ចសន្យាការងារនិយោជិតទៅមន្ទីរការងារពិតមែន។

២២- លិខិតចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ របស់ក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ជម្រាបមកក្រុមប្រឹក្សា-អាជ្ញាកណ្តាល ស្តីពីក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប កិច្ចសន្យាការងារជាមួយអាកាសយានដ្ឋានកម្ពុជា, សៀមរាប។

២៣- លិខិតបដិសេធលេខ ០៤០/២០ លបស/អសស ចុះថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ របស់លោក ប៉ូល ក្លេមិន (Paul CLEMENTS) ជាប្រធានចាត់ការទូទៅ (ស្តីទី) ក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពី ១. ការបដិសេធចំពោះការទាមទារប្រាក់ឈ្នួល និងអត្ថប្រយោជន៍ក្នុងខែមេសា និងឧសភា ឆ្នាំ២០២០។ ២. បដិសេធ ចំពោះភាពមិនត្រឹមត្រូវនៃតារាងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ដែលផ្តល់ជូនដោយតំណាងសហជីព។

២៤- លិខិតស្នើសុំលេខ ០០២/២០២០ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ របស់ក្រុមហ៊ុន EnviroCam គោរពជូនលោកអគ្គនាយក ស្តីពីសំណើសុំតម្លើងប្រាក់បៀវត្សរ៍ប្រចាំឆ្នាំដល់បុគ្គលិកប្រចាំព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងព្រលានយន្តហោះអន្តរជាតិសៀមរាប។

២៥- កំណត់ហេតុលើកទីពីរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩។

២៦- ឯកសារជាភាសាបរទេស។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតចាត់តាំងលេខ ០៨/២០ ACILS ចុះថ្ងៃអង្គារ ១៣រោច ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ របស់មជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ គោរពជូន ប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីចាត់តាំងឈ្មោះ ព្រិត សុអួត មន្រ្តីច្បាប់ ចូលរួមដោះស្រាយសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។

២- លិខិតលេខ ០០១១ ស.ជ.ក ចុះថ្ងៃអង្គារ ៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា គោរពជូនលោក វីលលៀម ខន់គ្លីន នាយកនៃមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាព ការងារអន្តរជាតិ ស្តីពីផ្ទេរសិទ្ធិជូនលោក ព្រិត សុអួត មន្រ្តីច្បាប់នៃមជ្ឈមណ្ឌលអាមេរិកកាំង សម្រាប់សាមគ្គីភាពការងារអន្តរជាតិ ដើម្បីជួយអម និងដោះស្រាយគ្រប់និតិវិធី នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ការស្នាក់នៅ និងថ្លៃអាហារបីពេល។

៣- លិខិតលេខ ០០៤/២០. សកអអកកអសសត. ចុះថ្ងៃអង្គារ ១កើត ខែផល្គុន ឆ្នាំកុរ ទោស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់សហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោក រ៉េន រ៉ាវ៉ាន់ ប្រធានសហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា ស្តីពីស្នើសុំពឹងពាក់ និងផ្ទេរសិទ្ធិជូនលោកជួយដោះស្រាយ វិវាទការងាររួមរបស់សហជីពខ្ញុំ គ្រប់ និតិវិធីដោះស្រាយវិវាទការងាររួមទាំងក្នុងច្បាប់ និងក្រៅច្បាប់ ដែលបានដាក់ទៅមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប លេខ ០០៦/២០ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០។

៤- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប លេខ ០០១ ម.ក.ប ចុះថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩។

៥- លេខ ០០១ មកប ចុះថ្ងៃចន្ទ ៣រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹង ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់រដ្ឋមន្រ្តីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ជាអង្គការវិជ្ជាជីវៈមួយ បានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៦- លិខិតលេខ ០០៣/២០. សកអអកកអសសត. ចុះថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ របស់សហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីប្តឹងនិយោជកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប (HCC) និង ក្រុមហ៊ុនអាកាសយានដ្ឋានកម្ពុជា (CAMS/VINCI) ដែលបានកាត់បន្ថយប្រាក់ឈ្នួលកម្មករនិយោជិតធ្វើឱ្យប៉ះពាល់ជីវភាពប្រចាំថ្ងៃយ៉ាងខ្លាំង។

៧- លិខិតលេខ ០២០/២០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់នាយកក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីសំណើសុំព្យួរការងារកម្មករនិយោជិតចំនួន ១១៦នាក់ រយៈពេល ២ខែ។

៨- លិខិតលេខ ០០៦/២០ សកអអកកអសសគ. ចុះថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ របស់សហជីពកម្មករនិយោជិត អាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនសារណានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប។

៩- បញ្ជីឈ្មោះកម្មករនិយោជិតនៃក្រុមហ៊ុន HCC សម្រាប់ទាមទារប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ ក្នុងខែមេសា ខែឧសភា។

១០- លិខិតលេខ ០០៧/២០ សកអអកកអសសគ. ចុះថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ របស់សហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សា-អាជ្ញាកណ្តាល ស្តីពីបដិសេធឯកសារកស្តុតាង និងទឡ្ហីករណ៍របស់ក្រុមហ៊ុន ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប លេខ ០៣១ ម.ក.ប ចុះថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប លេខ ០០២/២០ ម.ក.ប ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៨៥ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៨៦ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
ARBITRATION COUNCIL

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្តល់សេវាកម្មអនាម័យ ប្រមូលសម្រាម និងមានជួលកម្មករនិយោជិតសរុបចំនួន ១៦៣នាក់ *(យោងតាមរបាយការណ៍ ស្តីពីការដោះស្រាយវិវាទការងាររួមរវាងក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប និងសហជីពកម្មករនិយោជិតអាកាសយានដ្ឋានអន្តរជាតិកម្ពុជានៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប)*។

**ចំណុចវិវាទទី១ និងទី២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជករក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតជាធម្មតា ដោយមិនមានកាត់បន្ថយអត្ថប្រយោជន៍ណាមួយឡើយ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលពេញ ១០០ភាគរយ ប្រាក់ថ្លៃអាហារ និងប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវនៅក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០ (សែសិប)នាក់។

| ល.រ | ឈ្មោះ | តួនាទី |
|---|---|---|
| ១ | ធិក ទាវ | អ្នកសំអាត |
| ២ | ហ៊ិន ប៊ុនហ៊ុន | អ្នកសំអាត |
| ៣ | ឡី ស្រីអូន | អ្នកសំអាត |
| ៤ | រឿន ចាន់សេរីរ័ត្ន | អ្នកសំអាត |
| ៥ | ឡី សំណាង | អ្នកសំអាត |
| ៦ | ទូច ព្រម | អ្នកសំអាត |
| ៧ | សោម ស៊ីនុន | អ្នកសំអាត |
| ៨ | ភោគ ឡាប | អ្នកសំអាត |
| ៩ | សោម សុគន្រ៍ | អ្នកសំអាត |
| ១០ | សុទ្ធ សុណាក់ | អ្នកសំអាត |
| ១១ | រឿម ព្រេម | អ្នកសំអាត |
| ១២ | ស្រី ដាវ៉ានី | អ្នកសំអាត |
| ១៣ | ខៀវ ច័ន្ទនីម | អ្នកសំអាត |
| ១៤ | ធុន សារដ្ឋ | អ្នកសំអាត |
| ១៥ | រឿន គីមរិន | អ្នកសំអាត |
| ១៦ | ភោគ សារឿយ | អ្នកសំអាត |
| ១៧ | ហ៊ឹម អ៊ីន | អ្នកសំអាត |
| ១៨ | ស៊ិន់ គា | អ្នកសំអាត |
| ១៩ | យៅ ពុទ្ធី | អ្នកសំអាត |
| ២០ | ឈន ប្រុសនាង | អ្នកសំអាត |
| ២១ | ធុន ធុត | អ្នកសំអាត |
| ២២ | ញូង ព្រម | អ្នកសំអាត |
| ២៣ | ឈុន សំនៀង | អ្នកសំអាត |

THE ARBITRATION COUNCIL

| | | |
|---|---|---|
| ២៤ | ហូរ ពៅ | អ្នកសំអាត |
| ២៥ | យង់ ឯម | អ្នកសំអាត |
| ២៦ | នឿន វណ្ណេត | ប្រធានក្រុម |
| ២៧ | ធុន បារាំង | ប្រធានក្រុម |
| ២៨ | វង់ រួន | អ្នកសំអាត |
| ២៩ | ទេព សុភ័ណ្ឌ | អ្នកសំអាត |
| ៣០ | ខាំ សុភា | អ្នកសំអាត |
| ៣១ | ជិន និមល | អ្នកសំអាត |
| ៣២ | ជួប វល័ក្ខ | អ្នកសំអាត |
| ៣៣ | ឡាយ គីមឡុង | អ្នកសំអាត |
| ៣៤ | ជឿង ពៅ | អ្នកសំអាត |
| ៣៥ | គាំ កាន | អ្នកសំអាត |
| ៣៦ | ហ៊ួង លីហៀង | ជំនួយការក្រុម |
| ៣៧ | ផែម ភីរម្យ | អ្នកសំអាត |
| ៣៨ | រឿន យី | អ្នកសំអាត |
| ៣៩ | នឿម គា | អ្នកសំអាត |
| ៤០ | យុត សារ៉ែន | អ្នកសំអាត |

- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ និយោជកបានប្រជុំជាមួយកម្មករនិយោជិតទាំងអស់ ដើម្បីជូនដំណឹងអំពីការសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១១៦នាក់ ចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ លើកលែងតែកម្មករនិយោជិតចំនួន ៧នាក់ ដែលនៅបន្តធ្វើការ។
  - ចាប់ពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ រហូតមកដល់បច្ចុប្បន្ន (ថ្ងៃសវនាការ) និយោជកមិនមានការងារឱ្យកម្មករនិយោជិតចំនួន ១១៦នាក់ ធ្វើនោះទេ។ ប៉ុន្តែ និយោជកបានបើកប្រាក់ឈ្នួលប្រចាំខែមីនា ជូនកម្មករនិយោជិតទាំងអស់។ ចំណែកប្រាក់ឈ្នួលប្រចាំខែមេសា និងខែឧសភា ឆ្នាំ២០២០ និយោជកមិនបានបើកជូនកម្មករនិយោជិតទាំងអស់នោះទេ។
  - មុនពេលព្យួរកិច្ចសន្យា កម្មករនិយោជិតទទួលបានប្រាក់អត្ថប្រយោជន៍ផ្សេងៗ បន្ថែមពីលើប្រាក់ឈ្នួល ដូចជា ប្រាក់ថ្លៃអាហារចំនួន ៨ ដុល្លារអាមេរិក ក្នុងមួយខែ និងប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ (ថ្ងៃឈប់បុណ្យធម្មតាចំនួន ៣២០០០រៀល និងថ្ងៃឈប់បុណ្យចូលឆ្នាំខ្មែរ ឬភ្ជុំបិណ្ឌចំនួន ៣៥០០០រៀល) ជូនកម្មករនិយោជិតណាដែលមកធ្វើការថ្ងៃឈប់បុណ្យទាំងនោះ។
  - និយោជកមិនមានការអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាបនោះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ គឺមិនត្រឹមត្រូវតាមមាត្រា ៧១ និងមាត្រា ៧២ នៃច្បាប់ស្តីពីការងារ។

- ○ និយោជកមិនមានមូលហេតុត្រឹមត្រូវក្នុងការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត។
- ○ និយោជកបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិតដោយមិនមានការជូនដំណឹង។
- ○ និយោជកមិនបានបង្ហាញឯកសារណាមួយដែលបញ្ជាក់ថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារនោះទេ។
- ○ លើសពីនេះទៀត និយោជកបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិត មុនពេលអធិការការងារចុះត្រួតពិនិត្យក្រុមហ៊ុន និងមុនពេលមានការអនុញ្ញាត។
- ○ កម្មករនិយោជិតមានប្រាក់ឈ្នួលចន្លោះពី ១៥៦ដុល្លារអាមេរិក ទៅ ២០០ ដុល្លារអាមេរិក។

- ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយហេតុថា ៖
  - ○ ក្រុមហ៊ុនមានផលប៉ះពាល់ខ្លាំង ដោយសារអាកាសយានដ្ឋានអន្តរជាតិកម្ពុជាមិនមានភ្ញៀវធ្វើដំណើរទាល់តែសោះក្នុងអំឡុងពេលប៉ុន្មានខែចុងក្រោយនេះ ព្រោះតែវិបត្តិវីរុសកូវីដ១៩ ហើយក្រុមហ៊ុនបាត់បង់ចំណូលស្ទើរតែទាំងស្រុង។
  - ○ នៅរសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ អាកាសយានដ្ឋានអន្តរជាតិកម្ពុជាបានទាក់ទងទៅក្រុមហ៊ុនតាមរយៈទូរស័ព្ទ ស្នើសុំឱ្យកាត់បន្ថយបុគ្គលិកមកត្រឹមតែ ៦នាក់ ដោយមូលហេតុអាកាសយានដ្ឋានអន្តរជាតិកម្ពុជាលែងមានសកម្មភាពហោះហើរ និងអត់មានការងារឱ្យធ្វើ។
  - ○ និយោជកបានរក្សាកម្មករនិយោជិតរួមទាំងអ្នកគ្រប់គ្រងផង ឱ្យនៅសល់ចំនួន ១៦នាក់ ក្នុងខែមេសា ហើយកាត់បន្ថយសល់ចំនួន ៩នាក់ ក្នុងខែឧសភា។
  - ○ និយោជកបានពិភាក្សាជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ហើយមន្ត្រីរបស់មន្ទីរបានណែនាំនិយោជកឱ្យព្យួរកិច្ចសន្យាការងារ។ និយោជកបានដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ប៉ុន្តែដោយសារមានបញ្ហាខុសទម្រង់ឯកសារនៃការស្នើសុំព្យួរកិច្ចសន្យាការងារ និងខ្វះខាតឯកសារ ទើបនិយោជកត្រូវចំណាយពេលរៀបចំទម្រង់ឯកសារសុំព្យួរកិច្ចសន្យាការងារទៅមន្ទីរការងារចំនួន ៣លើក ដែលលើកចុងក្រោយ គឺនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០។
  - ○ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យស្នើសុំព្យួរកិច្ចសន្យាការងារនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ និងបានបញ្ជាក់ថាអធិការការងារនឹងចុះទៅពិនិត្យស្ថានភាពក្រុមហ៊ុននៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០។ ក្រោយមក អធិការការងារបានជូនដំណឹងតាមរយៈទូរស័ព្ទមកនិយោជកថា សុំពន្យារការចុះពិនិត្យស្ថានភាពក្រុមហ៊ុន។ រហូតមកដល់ថ្ងៃសវនាការ អធិការការងារមិនទាន់បានចុះមកពិនិត្យស្ថានភាពក្រុមហ៊ុននៅឡើយទេ។
  - ○ ក្រុមហ៊ុនមានចំណូលតិចជាង ១០ភាគរយ ដោយសារតែវិបត្តិវីរុសកូវីដ១៩។ ហេតុនេះ និយោជកសុំឱ្យកម្មករនិយោជិតយល់ពីផលលំបាករបស់ក្រុមហ៊ុន ព្រោះក្រុមហ៊ុនមិនមានលទ្ធភាពផ្តល់ជូនតាមការទាមទារទេ។
  - ○ ពេលស្ថានភាពក្រុមហ៊ុនប្រសើរឡើង និយោជកនៅតែត្រូវការកម្មករនិយោជិតមកបម្រើការងារវិញ ដោយរក្សាអត្ថប្រយោជន៍ផ្សេងៗ និងអតីតភាពជូនកម្មនិយោជិតដដែល។

- យោងតាមឯកសាររបស់ភាគីកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ០ សារណា និងបញ្ជីឈ្មោះកម្មករនិយោជិតចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ ស្ដីពីប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍កម្មករនិយោជិតនៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប ដែលជាដើមបណ្ដឹង សរុបចំនួន ៤០នាក់ ត្រូវទទួលបានពីការទាមទារប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ នៅខែមេសា និងខែឧសភា ឆ្នាំ២០២០។ (សូមមើលតារាងក្នុងឧបសម្ព័ន្ធ១)

- យោងតាមឯកសាររបស់ភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖
  - ០ ចំណុច "ឃ" ប្រការ៦ នៃបទបញ្ញត្តិ និងលក្ខខណ្ឌទូទៅចំពោះកម្មករនិយោជិត និងថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន EnviroCam (អេច ស៊ី ស៊ី គ្រុប) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ៖ "*ក្រៅពីប្រាក់បៀវត្សរ៍ កម្មករនិយោជិតទាំងអស់ ទទួលបានប្រាក់ឧបត្ថម្ភចំនួន ៥ ដុល្លារអាមេរិក ជារៀងរាល់ខែ សម្រាប់ឧបត្ថម្ភលើការចំណាយថ្លៃអាហារ។*"
  - ០ និយោជកបានដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតទៅមន្ទីរការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តសៀមរាប ចំនួន ៣លើក។ លើកទី១ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០, លើកទី២ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ និងលើកទី៣ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០២០។
  - ០ លិខិតលេខ ០០២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ នៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប សម្រេចតម្លើងប្រាក់ឈ្នួលគោល និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០។ ទឹកប្រាក់ដែលត្រូវទទួលបានមានដូចជា ប្រាក់ឈ្នួលគោល ១៥៦ដុល្លារអាមេរិក ថ្លៃអាហារ ៨ដុល្លារអាមេរិក ថ្លៃបុណ្យធម្មតា ៣,៣០០០រៀល និងបុណ្យចូលឆ្នាំខ្មែរ ឬភ្ជុំបិណ្ឌ ៣៦,០០០រៀល។
  - ០ លិខិតលេខ ០០៩ មបក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តសៀមរាប បញ្ជាក់ពីការទទួលបានលិខិតស្នើសុំព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ និងការអះអាងពីការអនុវត្តបែបផែនថ្មីក្នុងការស្នើសុំព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធអនឡាញ ដែលជាហេតុមន្ទីរមិនអាចចេញលិខិតអនុញ្ញាតជូនក្រុមហ៊ុនបាន។
  - ០ លិខិតបដិសេធរបស់ភាគីនិយោជកលេខ ០៤០/២០ លបស/អសស ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០២០ (១) បដិសេធចំពោះការទាមទារប្រាក់ឈ្នួល និងអត្ថប្រយោជន៍ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ (២) បដិសេធចំពោះភាពមិនត្រឹមត្រូវនៃតារាងប្រាក់ឈ្នួល និងអត្ថ-ប្រយោជន៍ដែលផ្ដល់ជូនដោយតំណាងសហជីព។

**ហេតុផលនៃសេចក្ដីសម្រេច ៖**

**ចំណុចវិវាទទី១ និងទី២ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួល ១០០ភាគរយ, ប្រាក់ថ្លៃអាហារ និងប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០ (សែសិប) នាក់**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្ដល់ប្រាក់ឈ្នួល ១០០ ភាគរយ, ប្រាក់ថ្លៃអាហារ និងប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតដែរ ឬទេ?

**ក. ករណីប្រាក់ឈ្នួល ១០០ ភាគរយ**

ចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ *"ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពី ពីរខែ។ ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ៥៨/០៧-៨ ស្តារ ស្តតវែរ បានបកស្រាយចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ខាងលើថា ៖ *"ការលំបាកផ្នែកសំភារៈ ឬសេដ្ឋកិច្ចធ្ងន់ធ្ងរនេះ ជាហេតុផលដែលអាចអនុញ្ញាតឱ្យនិយោជកអាចព្យួរការងារ ប្រសិនបើនិយោជកបំពេញលក្ខខណ្ឌ ២យ៉ាងគឺ ៖*

*- ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ និង*

*- ការព្យួរការងារនេះមិនត្រូវឱ្យលើសពី ២ខែ។"*

នៅក្នុងហេតុផលនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ បានបកស្រាយចំណុចទី១១ នៃមាត្រា ៧១ ថា ៖ *"ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ គឺមានន័យថា និយោជកត្រូវគោរពតាមកាតព្វកិច្ចនៃការជូនដំណឹង និងទទួលបានការអនុញ្ញាតជាមុនពីអធិការការងារ ទើបអាចព្យួរការងារដោយស្របច្បាប់បាន។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២២/០៥-អូសេអង់ ហេតុផលនៃចំណុចវិវាទទី២, លេខ ៧២/០៥-ណាត ហ្គេអឹជី ហេតុផលនៃចំណុចវិវាទទី១, លេខ ០៨/០៧-ស៊ាវ គីញ ហេតុផលនៃចំណុចវិវាទទី២, លេខ ១៩៨/១៣-ស៊ូ អ៊ីកែរីល (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី២, លេខ ១៦០/១៤-អូសេអង់ ហ្គាមិន ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១, លេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី ហេតុផលនៃចំណុចវិវាទទី១)*

លើសពីនេះ ចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារដដែល ចែងថា ៖ *"ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់តែកាតព្វកិច្ចសំខាន់ៗនៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត។"*

ផ្អែកតាមចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារខាងលើ ក្នុងករណីដែលមានការព្យួរកិច្ចសន្យាការងារ ដូចមានចែងក្នុងចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ គឺនិយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតទេ ចំណែកឯកម្មករនិយោជិតក៏មិនមានកាតព្វកិច្ចក្នុងការធ្វើការឱ្យនិយោជកផងដែរ។ ប៉ុន្តែ ចំណុចទី១ នៃមាត្រា ៧២ ខាងលើ ត្រូវបានអនុវត្តនៅពេលដែលការព្យួរកិច្ចសន្យាការងារធ្វើឡើងដោយស្របតាមនីតិវិធីច្បាប់ប៉ុណ្ណោះ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ *"ប្រសិនបើក្រុមហ៊ុនបានធ្វើបែបបទព្យួរការងារត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដោយការព្យួរកិច្ចសន្យាការងារនោះ ត្រូវបានស្ថិតនៅក្រោមការត្រួតពិនិត្យពីអធិការកិច្ចការងារនោះ ក្រុមហ៊ុនមិនមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតឡើយ។ ប៉ុន្តែ ប្រសិនបើក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្តីពីការងារ នៃការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ដូចបានរៀបរាប់ខាងលើទេនោះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ ភាគរយ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ដល់កម្មករនិយោជិត ទោះបីជាក្រុមហ៊ុនពុំមានការងារឱ្យកម្មករនិយោជិតធ្វើក៏ដោយ។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២១/០៣-ឡយ អ័ល ខេមបូឌា ហេតុផលនៃចំណុចវិវាទទី៨, លេខ ៦០/០៦-ញូវមេក ហ្គាមេន ហេតុផលនៃចំណុចវិវាទទី២, លេខ ៧៤/០៧-គួបល*

*អាប៉ាវែល ហេតុផលនៃចំណុចវិវាទទី១, លេខ ២៧/០៨-អាក ឃីត ហេតុផលនៃចំណុចវិវាទទី៦, លេខ ១០៩/០៩-យូ អេស អេ ហេតុផលនៃចំណុចវិវាទទី៤, លេខ ០០៨/១៧-ឋបរើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី ចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមឯកសារភស្តុតាងរបស់ភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា ភាគីនិយោជកបានដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារកម្មករចំនួន៣លើក ចាប់ពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ និងលើកចុងក្រោយ គឺនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០។ ដោយឡែក យោងតាមលិខិតលេខ ០០៩ មបក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ផ្ញើជូននិយោជក នៃក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប មានខ្លឹមសារបញ្ជាក់ពីការទទួលបានលិខិតស្នើសុំព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ និងការអះអាងរបស់មន្ទីរពីការអនុវត្តបែបផែនថ្មីក្នុងការស្នើសុំព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធអនឡាញ ដែលជាហេតុខាងមន្ទីរមិនអាចចេញលិខិតអនុញ្ញាតជូនក្រុមហ៊ុនបាន។ ជាមួយគ្នានេះដែរ នៅក្នុងសវនាការ ភាគីទាំងពីរទទួលស្គាល់ថា និយោជកបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចាប់ពីថ្ងៃទី២៥ ខែមីនា រហូតដល់ខែឧសភា ឆ្នាំ២០២០ ដោយសារមិនមានការងារឱ្យកម្មករនិយោជិតធ្វើ ប៉ុន្តែ ការព្យួរនេះមិនទាន់មានលិខិតអនុញ្ញាតពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប នោះទេ។

ហេតុនេះហើយ យោងតាមចំណុចទី១១ មាត្រា ៧១ និងចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារ និងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការព្យួរកិច្ចសន្យាការងាររបស់ក្រុមហ៊ុន អេច ស៊ី ស៊ី គ្រុប មិនបានធ្វើឡើងស្របតាមនីតិវិធីនៃច្បាប់ស្តីពីការងារនៅឡើយទេ ពីព្រោះថា ការព្យួរកិច្ចសន្យាការងារនេះ មិនមានលិខិតអនុញ្ញាតពីអធិការការងារ ទោះបីជានិយោជកបានព្យាយាមដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ទៅមន្ទីរការងារក៏ដោយ ប៉ុន្តែលិខិតនោះ នៅមិនទាន់មានការអនុញ្ញាតនៅឡើយ។ ហេតុនេះ និយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០(សែសិប)នាក់។

**ខ. ករណីប្រាក់ថ្លៃអាហារ**

មាត្រា ១០៣ នៃច្បាប់ស្តីពីការងារ ចែងថា ៖ ប្រាក់ឈ្នួលមានជាអាទិ៍ដូចតទៅ ៖

- *"ប្រាក់ឈ្នួលសុទ្ធសាធ*
- *ប្រាក់បន្ថែមម៉ោង*
- *កំរៃជើងសា*
- *បុព្វលាភ និងប្រាក់បំណាច់*
- *ភាគកម្មក្នុងប្រាក់ចំណេញ*
- *ប្រាក់ដែលបើកជារង្វាន់*
- *តម្លៃអត្ថប្រយោជន៍ជាវត្ថុ*
- *វិភាជន៍គ្រួសារសំរាប់ភាគដែលលើសពីទឹកប្រាក់ត្រឹមត្រូវតាមច្បាប់*
- *វិភាជន៍សំរាប់ការឈប់សំរាក ឬបំណាច់សំរាប់ទូទាត់ការឈប់សំរាក*

- *ចំនួនប្រាក់ដែលនិយោជកត្រូវផ្តល់ឱ្យក្នុងពេលបាត់បង់សមត្ថភាពពលកម្ម និងក្នុងពេលលំហែមាតុភាព។"*

យោងតាមចំណុច "ឃ" ប្រការ៦ នៃបទបញ្ញត្តិ និងលក្ខខណ្ឌទូទៅចំពោះកម្មករនិយោជិត និងថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន EnviroCam (អេច ស៊ី ស៊ី គ្រុប) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ចែងថា ៖ *"ក្រៅពីប្រាក់បៀវត្សរ៍ កម្មករនិយោជិតទាំងអស់ ទទួលបានប្រាក់ឧបត្ថម្ភចំនួន ៥ដុល្លារអាមេរិក ជារៀងរាល់ខែ សម្រាប់ឧបត្ថម្ភលើការចំណាយថ្លៃអាហារ។"*

យោងតាមខ្លឹមសារ មាត្រា ១០៣ នៃច្បាប់ស្តីពីការងារ និង ចំណុច "ឃ" ប្រការ៦ នៃបទបញ្ញត្តិ និងលក្ខខណ្ឌទូទៅចំពោះកម្មករនិយោជិត និងថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន EnviroCam (អេច ស៊ី ស៊ី គ្រុប) ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រាក់ថ្លៃអាហារចំនួន ៨ដុល្លារអាមេរិក ក្នុងមួយខែ ដែលនិយោជកផ្តល់ឱ្យកម្មករនិយោជិត គឺមិនមែនជាប្រាក់ឈ្នួលនោះទេ ប៉ុន្តែ ជាប្រាក់ឧបត្ថម្ភដែលនិយោជកផ្តល់ឱ្យកម្មករនិយោជិតក្នុងគោលបំណងលើកទឹកចិត្តដល់កម្មករនិយោជិតដែលបានបំពេញការងារ។

ទន្ទឹមគ្នានេះដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០៤០/១៧-ខលធីលេ វីលេច វីហ្សេត (ភូមិវប្បធម៌) ហេតុផលនៃចំណុចវិវាទទី៤ បានបកស្រាយថា ៖ *"ប្រាក់ឧបត្ថម្ភថ្លៃបាយមិនមែនជាប្រាក់ឈ្នួលនោះទេ ប៉ុន្តែ ជាប្រាក់ឧបត្ថម្ភមួយដែលនិយោជកផ្តល់ឱ្យកម្មករនិយោជិតប្រសើរលើសពីច្បាប់ស្តីពីការងារ ហើយត្រូវបានផ្តល់ឱ្យក្នុងគោលបំណងលើកទឹកចិត្តដល់កម្មករនិយោជិត ដែលមកបំពេញការងារ មិនមែនសម្រាប់កម្មករនិយោជិតដែលអវត្តមានពីការងារនោះទេ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។ នៅក្នុងករណីនេះ និយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើនោះទេក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ថ្លៃអាហារនៅពេលកម្មករនិយោជិតមិនមានការងារធ្វើក្នុងខែមេសា និងខែឧសភា ឆ្នាំ ២០២០ នោះទេ។

**គ. ករណីប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ**

មាត្រា ១៣៧ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"គ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពីប្រាំបីម៉ោង ក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងម៉ោង ក្នុងមួយអាទិត្យ ឡើយ។ តាមអត្ថន័យនៃមាត្រា ១៣៧ នៃច្បាប់ស្តីពីការងារខាងលើនេះ មានន័យថា ថិរវេលាធ្វើការធម្មតារបស់កម្មករនិយោជិតមិនត្រូវលើស ៨ម៉ោង ក្នុងមួយថ្ងៃ ឬ ៤៨ម៉ោង ក្នុងមួយសប្តាហ៍ ឡើយ ។"*។

មាត្រា ១៦៤ នៃច្បាប់ស្តីពីការងារ ចែងថា៖ *"នៅក្នុងគ្រឹះស្ថាន សហគ្រាសណា ដែលមិនអាចបញ្ឈប់ការងារបាន ដោយសកម្មភាពរបស់ខ្លួនតម្រូវកម្មករនិយោជិតទាំងឡាយដែលជាប់ធ្វើការនៅក្នុងថ្ងៃឈប់បុណ្យត្រូវមានសិទ្ធិទទួលក្រៅពីប្រាក់ឈ្នួលដែលខ្លួនបានធ្វើនូវប្រាក់បំណាច់មួយ ដែលនៅលើបន្ទុកនិយោជកដែរ ហើយដែលកំណត់ក្នុងប្រកាសក្រសួងទទួលបន្ទុកវិស័យការងារ។"*។

ប្រការ ២ នៃប្រកាសលេខ ១០ សកបយ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ចែងថា ៖ *" ក្នុងករណីចាំបាច់ដែលគ្រឹះស្ថាន ឬសហគ្រាសមិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសថ្ងៃឈប់បុណ្យ ដូចមានចែងក្នុង*

*ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ម្ចាស់ ឬនាយកគ្រឹះស្ថានសហគ្រាស អាចសំរបសំរួលជាមួយកម្មករនិយោជិតរបស់ខ្លួនឱ្យធ្វើការនៅថ្ងៃឈប់បុណ្យនេះបាន។"*

ប្រការ ៤ នៃប្រកាសដដែល ចែងថា ៖ " *កម្មករនិយោជិតដែលធ្វើការថ្ងៃឈប់បុណ្យ មានសិទ្ធិទទួលបាននូវប្រាក់បំណាច់មួយ ដែលស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។..."* ។

នៅក្នុងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៥២/១២-៨ស្តារ ស្តូតវ៉េរ ហេតុផលនៃចំណុចវិវាទទី២ អាជ្ញាកណ្ដាលបានបកស្រាយមាត្រា ១៣៧ និងមាត្រា ១៦៤ នៃច្បាប់ស្ដីពីការងារ ប្រការ២ និងប្រការ៤ នៃប្រកាសលេខ ១០ សកបយ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ខាងលើថា ៖ *"ការដែលកម្មករនិយោជិតមកធ្វើការនៅថ្ងៃបុណ្យ គឺដូចជាកម្មករនិយោជិតមកធ្វើការនៅថ្ងៃធម្មតាដែរ ប៉ុន្តែ វាខុសគ្នាត្រង់ថា ថ្ងៃបុណ្យនេះ កម្មករនិយោជិតមានសិទ្ធិឈប់សម្រាកដោយមិនកាត់ប្រាក់ឈ្នួលទេ ហើយបើកម្មករនិយោជិតមកធ្វើការ កម្មករនិយោជិតមានសិទ្ធិទទួលបាននូវប្រាក់បំណាច់មួយដែលស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។ នេះបានន័យថា បានប្រាក់ឈ្នួលបន្ថែម ១ថ្ងៃទៀត ទៅលើប្រាក់ឈ្នួលដែលកម្មករនិយោជិតត្រូវទទួលបានក្នុងមួយខែ កាលបើកម្មករនិយោជិតមកធ្វើការមិនឈប់សម្រាកនៅថ្ងៃបុណ្យ។" (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ០៧១/១៩-អេ អិម ៣ (ខេមបូឌា) ហ្គាមេន ហេតុផលនៃចំណុចវិវាទទី៣, លេខ ០៨៨/១៩-ខូលលីជី តេក្សស្ទីល ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៣)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងមុនៗដែរ។

យោងតាមអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា ចំពោះកម្មករនិយោជិតណាដែលស្ម័គ្រចិត្តមកធ្វើការថ្ងៃឈប់បុណ្យ និយោជកនឹងផ្ដល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យជូនកម្មករនិយោជិតចំនួន ៣២០០០រៀល ចំពោះថ្ងៃឈប់បុណ្យធម្មតា និងចំនួន ៣៥០០០រៀល ចំពោះថ្ងៃឈប់បុណ្យចូលឆ្នាំខ្មែរ ឬភ្ជុំបិណ្ឌ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតមិនមានការងារធ្វើនោះទេ នៅក្នុងខែមេសា និងខែឧសភាឆ្នាំ ២០២០ ដោយសារតែការធ្លាក់ចុះជើងហោះហើរ ហើយនិយោជកបានព្យួរកិច្ចសន្យាការងាររបស់ពួកគាត់។ ក្នុងករណីនេះ មានន័យថា កម្មករនិយោជិតមិនបានមកធ្វើការនៅថ្ងៃឈប់បុណ្យដែលតម្រូវឱ្យនិយោជកទូទាត់ប្រាក់បំណាច់ថ្ងៃឈប់បុណ្យជូនពួកគាត់នោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចផ្ដល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ ក្នុងខែមេសា និងខែឧសភា ជូនកម្មករនិយោជិតឡើយ។

យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច ដូចខាងក្រោម ៖

- បង្គាប់ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួល ១០០ភាគរយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០(សែសិប)នាក់។
- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្ដល់ប្រាក់ថ្លៃអាហារ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០ (សែសិប)នាក់។
- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០(សែសិប) នាក់។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ និងទី២ ៖ ៖**

- បង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០(សែសិប) នាក់។
- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ថ្លៃអាហារ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០ (សែសិប) នាក់។
- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលធ្វើការថ្ងៃឈប់បុណ្យ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោ-ជិតចំនួន ៤០(សែសិប) នាក់។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **យូ សួនទី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

**ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ៖ ០២៩/២០ - អេច ស៊ី ស៊ី គ្រុប**

## យោបល់ជំទាស់ទៅលើសេចក្តីសម្រេច
## នៃសំណុំរឿងលេខ ០២៩/២០ - អេច ស៊ី ស៊ី គ្រុប
## ដោយអាជ្ញាកណ្តាល យូ សួនទី ដែលជ្រើសរើសដោយភាគីនិយោជក

ប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចែងថា *"ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រារាល់សេចក្តីម្រេចរបស់ខ្លួនក្នុងសេចក្តីបង្គាប់មួយ ដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣រូប។* ***ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់មិនឯកភាពនឹងសេចក្តីសម្រេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្តីបង្គាប់នោះ"***។

យោងតាមប្រការនេះ ខ្ញុំអាជ្ញាកណ្តាល **យូ សួនទី** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងហេតុផលនៃសេចក្តីសម្រេចនៃសេចក្តីបង្គាប់លេខ **០២៩/២០-អេច ស៊ី ស៊ី គ្រុប** លើចំណុចវិវាទទី១ និងទី២ ត្រង់ទី១ ដែលបង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមិនត្រឹមត្រូវ ក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ជូនកម្មករនិយោជិតចំនួន ៤០(សែសិប) នាក់។

ខ្ញុំជំទាស់នឹងហេតុផលរបស់មតិភាគច្រើនក្នុងការធ្វើសេចក្តីសម្រេចខាងលើ ដោយមានមូលហេតុដូចខាងក្រោម ៖

ចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាស មិនលើសពី ពីរខែ។ ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។"*

ខ្ញុំយល់ថា ចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ កំណត់ថា ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ ហើយការព្យួរការងារនេះ មិនត្រូវឱ្យលើសពី ២ខែ ឡើយ។ យោងតាមអង្គហេតុនៅក្នុងសំណុំរឿងនេះ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ និយោជកបានដាក់ពាក្យស្នើសុំព្យួរសកម្មភាពសហគ្រាសទៅអធិការកិច្ចការងារនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ហើយបានទទួល និងអនុវត្តតាមការណែនាំរបស់មន្ត្រីអធិការកិច្ចការងារនៅមន្ទីរការងារ និងបណ្តុះបណ្តាល ខេត្តសៀមរាប ពាក់ព័ន្ធនឹងទម្រង់នៃការដាក់ពាក្យស្នើសុំព្យួរកិច្ចសន្យាការងារនេះ។ ប៉ុន្តែ ការចុះធ្វើការត្រួតពិនិត្យនេះ ត្រូវបានអាក់ខានដោយសារតែមានភាពអាក់រអួលក្នុងការអនុវត្តវិធានរដ្ឋបាលនៅក្នុងអំឡុងពេលស្នើសុំព្យួរ ហើយក៏ជាអំឡុងពេលដែលមានការឆ្លងវីរុសកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា និងនៅទូទាំងពិភពលោកផងដែរ។

នៅក្នុងរយៈពេលនៃការព្យួរការងារនេះ គឺជាពេលដែលប្រជាពលរដ្ឋទូទាំងប្រទេសត្រូវតែអនុវត្តវិធានការការពារប្រឆាំងនឹងវីរុសកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល។ វត្តមាននៃវីរុសកូវីដ-១៩ នេះបានធ្វើឱ្យប៉ះពាល់ដល់វិស័យជាច្រើន ហើយនិយោជក និងកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ ក៏បានទទួលរងផលប៉ះពាល់ពីបញ្ហាទាំងនេះផងដែរ។ យោងតាមអង្គហេតុ និយោជកត្រូវបាត់បង់ចំណូលចំនួន ៩០% ហើយត្រូវកាត់បន្ថយសកម្មភាពការងារ និងព្យួរការងាររបស់កម្មករនិយោជិតរបស់ខ្លួនជាច្រើន។ ការកាត់បន្ថយ

សកម្មភាពការងារ និងការព្យួរការងារទាំងនេះ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់កម្មករនិយោជិត ជាពិសេស គឺប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ដែលពួកគេត្រូវទទួលបាននៅពេលបំពេញការងារជាធម្មតា។

តាមគោលការណ៍សមធម៌ និយោជក និងកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ គឺសុទ្ធតែបានទទួលរងនូវការខូចខាតដូចគ្នា។ នៅពេលដែលនិយោជកបានព្យាយាមអនុវត្តតាមនីតិវិធីនៃការព្យួរកិច្ចសន្យាការងារ ហើយ ប៉ុន្តែ ការអនុវត្តនេះមានការយឺតយ៉ាវដោយសារតែវិធានរដ្ឋបាល ដែលមិនមែនជាកំហុសរបស់និយោជក គួរគប្បីត្រូវបានសន្មតថា និយោជកបានបំពេញរួចរាល់ហើយ នូវកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តតាមនីតិវិធីនៃការព្យួរកិច្ចសន្យាការងារតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ដូច្នេះ ការតម្រូវឱ្យនិយោជកទទួលកាតព្វកិច្ចបង់ប្រាក់ឈ្នួល ឱ្យកម្មករនិយោជិតរបស់ខ្លួនក្នុងអំឡុងពេលនេះ គឺជាការដាក់បន្ថែមនូវបន្ទុកដែលមិនមានភាពសមធម៌សម្រាប់និយោជកឡើយ។

យោងតាមការបកស្រាយខាងលើ និយោជកពុំមានកាតព្វកិច្ចបង់ប្រាក់ឈ្នួលជូនកម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារក្នុងខែមេសា និងខែឧសភា ឆ្នាំ២០២០ ឡើយ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០

ហត្ថលេខារបស់អាជ្ញាកណ្តាល

យូ សួនទី

បញ្ជីឈ្មោះកម្មករនិយោជិតរោងចក្រស៊ីន HCC ដែលទាមទារប្រាក់ឈ្នួលនិងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ខែមេសា → ឧសភា

| ល.រ | ឈ្មោះ | ភេទ | តួនាទី | ប្រាក់ឈ្នួលគោល | អត្ថប្រយោជន៍ផ្សេងៗ (ប្រាក់ឧបត្ថម្ភ) +(ប្រាក់បុណ្យចូលឆ្នាំ 4 និងខែ 5) | សរុប |
|---|---|---|---|---|---|---|
| 01 | ម៉ក ធាវី | ស | អ្នកសំអាត | 181$ | 8$ + 35$ + 33$ | 446$ |
| 02 | ជិន ស៊ុនស៊ាន | ស | —॥— | 181$ | 8$ + 35$ + 33$ | 446$ |
| 03 | ស៊ី ស្រីមុំ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 04 | គ្រឹន ចាន់ថេវិត្តិ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 05 | ស៊ី សំណាង | ស | —॥— | 181$ | 8$ + 35$ + 33$ | 446$ |
| 06 | ឡុង ស្រមៃ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 07 | ចោម ស៊ុគុន | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 08 | ពេក ស្មាម | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 09 | ចោម សុគ្រុក | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 10 | សុខ សុណាក់ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 11 | គ្រឹម សុខាម | ស | —॥— | 171$ | 8$ + 35$ + 33$ | 426$ |
| 12 | ស្រី ណាវី | ស | —॥— | 181$ | 8$ + 35$ + 33$ | 446$ |
| 13 | ត្រុំ ប៊ុននីម | ស | —॥— | 171$ | 8$ + 35$ + 33$ | 426$ |
| 14 | ជុន ណារិទ្ធ | ស | —॥— | 176$ | 8$ + 35$ + 33$ | 436$ |
| 15 | គ្រឹម គីមរ៉ែន | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 16 | ពេក ណាគ្រឹម | ស | —॥— | 176$ | 8$ + 35$ + 33$ | 436$ |
| 17 | ជិម ភុន | ស | —॥— | 218,40$ | 23$ + 46$ + 48$ | 576,8 |
| 18 | ទីន គា | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 19 | អោក សុខឺ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 20 | ណាន ប្រុសាចាន់ | ប | —॥— | 218,40$ | 23$ + 46$ + 48$ | 576,80 |
| 21 | ភុន ភុត | ប | អ្នកសំអាត | 176$ | 8$ + 35$ + 33$ | 436$ |

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

បញ្ជីឈ្មោះកម្មករនិយោជិតក្រុមហ៊ុន HCC ត្រូវបានទាមទារប្រាក់ឈ្នួលដែលខ្វះប្រាក់អត្ថប្រយោជន៍ផ្សេងៗ ពីលេខ១ → ៤០

| ល.រ | ឈ្មោះ | ភេទ | តួនាទី | ប្រាក់ឈ្នួលគោល | ខ្វះ (ប្រាក់បំណាច់អតីតភាព) (ប្រាក់ខូចខាត) + (ប្រាក់ឈប់សម្រាកប្រចាំឆ្នាំ ៤ ទិវា S) | សរុប |
|---|---|---|---|---|---|---|
| 22 | ឡឹម ស្រាយ | ស | អ្នកតំរោត | 156$ | 8$ + 35$ + 33$ | 396$ |
| 23 | ឈុន ចាន់ធូ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 24 | អួន ស្រី | ស | —॥— | 171$ | 8$ + 35$ + 33$ | 426$ |
| 25 | ម៉ីន ផល | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 26 | កឿន វិចណ្ណា | ប | ប្រធានក្រុម | 212$ | 20$ + 34$ + 36$ | 534$ |
| 27 | ស៊ុន ធារ៉ាំង | ប | ប្រធានក្រុម | 211$ | 34$ + 36$ | 492$ |
| 28 | រ៉ុង រ៉ុន | ស | អ្នកតំរោត | 156$ | 8$ + 35$ + 33$ | 396$ |
| 29 | ពេជ្រ សុភក្តី | ស | —॥— | 218$,40 | 23$ + 46$ + 48$ | 576$,8[illegible] |
| 30 | ហ សុភា | ស | —॥— | 253$,40 | 23$ + 46$ + 48$ | 646$,80 |
| 31 | នឹម និមល | ស | —॥— | 253$,40 | 23$ + 46$ + 48$ | 646$,8[illegible] |
| 32 | ស៊ុំ វិចិត្រ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 33 | គួយ គឹមស៊ាង | ប | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 34 | កឿង ស្រី | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 35 | ភី ការ៉ន | ប | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 36 | ហ៊ុន ចាន់ណារិទ្ធ | ប | ជំនួយការក្រុម | 186$ | 8$ + 34$ + 36$ | 458$ |
| 37 | រិទ្ធ ចាន់ស្មី | ប | អ្នកតំរោត | 156$ | 8$ + 35$ + 33$ | 396$ |
| 38 | កឿន យ៉ី | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 39 | កឿង ការ | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| 40 | សុត សាវឿន | ស | —॥— | 156$ | 8$ + 35$ + 33$ | 396$ |
| | | | | | សរុប | 17,590 |

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL